**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

# សេចក្តីប្រកាសព័ត៌មាន

នៅថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០១៧ វេលាម៉ោង ៨:៣០ នាទីព្រឹក នៅទីស្តីការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានរៀបចំកិច្ចប្រជុំពិភាក្សាអំពី " **ដំណោះស្រាយករណីវិវាទពាក់ព័ន្ធនឹងដីសម្បទានសេដ្ឋកិច្ចដំណាំអំពៅផលិតស្ករសនាំចេញ** " នៅខេត្តចំនួន ៤ គឺ ខេត្តកោះកុង ខេត្តកំពង់ស្ពឺ ខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ ដឹកនាំដោយ **ឯកឧត្តម ជា សុផារ៉ា** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយមានការចូលរួមពី **ឯកឧត្តម ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឯកឧត្តម George Edgar ឯកអគ្គរដ្ឋទូតសហគមន៍អឺរ៉ុបប្រចាំនៅកម្ពុជា ឯកឧត្តម Walker SIMON តំណាងការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ឯកឧត្តម Nikolaos ZAIMIS តំណាង Directorate General of the European Commission for Trade ឯកឧត្តមអភិបាលខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ ខេត្តកំពង់ស្ពឺ និងឯកឧត្តមអភិបាលរងខេត្តកោះកុង តំណាងអង្គភាព និងអង្គការក្រៅរដ្ឋាភិបាលពាក់ព័ន្ធ។ លទ្ធផលនៃកិច្ចប្រជុំមានដូចតទៅ ÷

១. **ខេត្តកោះកុង** ÷ វិវាទរវាងប្រជាពលរដ្ឋនិងក្រុមហ៊ុន ហេង ហ៊ុយ, ក្រុមហ៊ុន Koh Kong Plantation Co.,Ltd និងក្រុមហ៊ុន Koh Kong Sugar Industry Co.,Ltd ÷

- បានដោះស្រាយបញ្ចប់វិវាទចំនួន ១៧ គ្រួសារ ពាក់ព័ន្ធជាមួយក្រុមហ៊ុន ហេង ហ៊ុយ និងបន្តដោះស្រាយជូនប្រជាពលរដ្ឋចំនួន ០៩ គ្រួសារដែលនៅសល់
- ទទួលដោះស្រាយប្រជាពលរដ្ឋចំនួន ១៧១ គ្រួសារ ដែលមិនទាន់បានដោះស្រាយ ក្នុងចំណោម ២០០ គ្រួសារ ដែលបានដាក់ពាក្យបណ្តឹងទៅសហគមន៍អឺរ៉ុប តាមគោលការណ៍ដែលធ្លាប់បានព្រមព្រៀងគ្នាជាមួយក្រុមហ៊ុន កាលពីឆ្នាំ ២០១៥ នូវដីទំហំ ៣០០ហិកតា ដែលបានត្រៀមរួចជាស្រេច ដោយមួយគ្រួសារទទួលបានដីទំហំ ១,៥០ ហិកតា។ ចំពោះចំណែកដីដែលនៅសល់ពី ២៩ គ្រួសារ ដែលទទួលបានការដោះស្រាយរួចកន្លងមក ទុកធ្វើជាហេដ្ឋារចនាសម្ព័ន្ធ។
- ទទួលយកមកពិនិត្យនិងស្វែងរកដំណោះស្រាយនូវសំណើរបស់ប្រជាពលរដ្ឋចំនួន ១៤០ គ្រួសារ ក្នុងចំណោម ១៧៥ គ្រួសារ ដោយ ១៦ គ្រួសារ ធ្លាប់ទទួលបានការដោះស្រាយរួច និង ១៩ គ្រួសារ មិនមានលក្ខខណ្ឌគ្រប់គ្រាន់



អាសយដ្ឋាន : ដីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

- មិនទទួលយកមកដោះស្រាយនូវប្រជាពលរដ្ឋចំនួន ២១១ គ្រួសារ ដែលបានមកបំពេញសលាកប័ត្រព័ត៌មាន ដែលក្នុងនោះ ១១៥ គ្រួសារ មានលក្ខខណ្ឌមិនគ្រប់គ្រាន់ ( ១០៨ គ្រួសារ មានអាយុមិនគ្រប់ការកាន់កាប់, ៦ គ្រួសារ ស្ម័គ្រចិត្ត និង ១ គ្រួសារ ដកពាក្យវិញ) និង ៩៦ គ្រួសារផ្សេងទៀត ធ្លាប់ទទួលបានដំណោះស្រាយរួចពីក្រុមហ៊ុន ក្នុងចំណោម ៦៧១ ដែលបានដោះស្រាយចន្លោះឆ្នាំ ២០០៦ - ២០១៥។

២. **ខេត្តកំពង់ស្ពឺ**÷វិវាទរវាងប្រជាពលរដ្ឋ និងក្រុមហ៊ុនភ្នំពេញស៊ូហ្គើរ, ក្រុមហ៊ុនកំពង់ស្ពឺស៊ូហ្គើរ និងក្រុមហ៊ុនកំពង់ស្ពឺផ្លេនថេសិន ÷

- អាជ្ញាធរខេត្តនឹងចុះធ្វើការផ្ទៀងផ្ទាត់ជាមួយសៀវភៅគ្រួសារនូវប្រជាពលរដ្ឋចំនួន ១៣ គ្រួសាររស់នៅស្រុកថ្ពង និងប្រជាពលរដ្ឋចំនួន ១៦៦ គ្រួសារ រស់នៅស្រុកឱរ៉ាល់ ដើម្បីកំណត់អ្នកដែលរងផលប៉ះពាល់ពិតប្រាកដ និងធ្វើការដោះស្រាយ
- ប្រគល់ភារកិច្ចជូនក្រុមការងារ និងអាជ្ញាធរខេត្ត បន្តពិនិត្យផ្ទៀងផ្ទាត់សលាកប័ត្រព័ត៌មានដែលក្រុមការងារទទួលបាន ដើម្បីរកអ្នកដែលមិនធ្លាប់ទទួលបានការដោះស្រាយ អ្នកដែលមិនព្រមទទួលយកការដោះស្រាយ អ្នកដែលបានដោះស្រាយរួចហើយ និងអ្នកដែលមិនពាក់ព័ន្ធនឹងករណីវិវាទ។

៣. **ខេត្តព្រះវិហារ**÷ វិវាទរវាងប្រជាពលរដ្ឋ និងក្រុមហ៊ុន ឡាន ហ្វេង (ខេមបូឌា) អ៊ិនវេស្ទមិន ខមភេនី លីមីធីត, ក្រុមហ៊ុន រូយ ហ្វេង (ខេមបូឌា) អ៊ិនវេស្ទមិន ខមភេនី លីមីធីត,ក្រុមហ៊ុន ហេង យូ (ខេមបូឌា) អ៊ិនវេស្ទមិន ខមភេនី លីមីធីត,ក្រុមហ៊ុន ហេង រូយ (ខេមបូឌា) អ៊ិនវេស្ទមិន ខមភេនី លីមីធីតនិងក្រុមហ៊ុន ហេង ណុង(ខេមបូឌា)អ៊ិនវេស្ទមិន ខមភេនី លីមីធីត÷

- បានដោះស្រាយបញ្ចប់វិវាទចំនួន១៣ គ្រួសារ ក្នុងចំណោម ២៤ គ្រួសារ ដែលបានព្រមព្រៀងជាមួយក្រុមហ៊ុននាពេលកន្លងមក និងបន្តដោះស្រាយអ្នកដែលនៅសេសសល់
- ពិនិត្យ និងដោះស្រាយជូនប្រជាពលរដ្ឋ ១៤ គ្រួសារ ដែលរងផលប៉ះពាល់ពិតប្រាកដ តែមិនធ្លាប់ទទួលបានការដោះស្រាយនាពេលកន្លងមក
- បន្តសម្របសម្រួលជាមួយប្រជាពលរដ្ឋចំនួន ១៨ គ្រួសារ ដែលមិនព្រមទទួលយកដំណោះស្រាយ
- មិនទទួលយកមកដោះស្រាយនូវប្រជាពលរដ្ឋចំនួន ២៣០ គ្រួសារដែលបានមកបំពេញសលាកប័ត្រព័ត៌មាន ក្នុងនោះ ៣០ គ្រួសារធ្លាប់ទទួលបានដំណោះស្រាយរួចកាលពីឆ្នាំ ២០១២ តាមរយៈការអនុវត្តបទបញ្ជាលេខ ០១ និង ២០០ គ្រួសារផ្សេងទៀតមិនជាប់ពាក់ព័ន្ធនឹងករណីវិវាទ
- ចំពោះសំណើរបស់សហគមន៍ជនជាតិដើមភាគតិចកួយចំនួន ៣ សហគមន៍ ដែលទាមទារចុះបញ្ជីដីសហគមន៍ជាកម្មសិទ្ធិសមូហភាពតាមផែនទីបឋមក្រៅផ្លូវការ រៀបចំដោយអង្គការពន្លកខ្មែរ គ្របដណ្តប់លើទីតាំងសាលាស្រុក សាលាឃុំ តំបន់ដែនជម្រកសត្វព្រៃព្រះរកា និងតម្រូវព្រៃឈើ

ក្រសួងនឹងពិនិត្យចាត់ចែងដោយឡែកតាមគោលការណ៍និងនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច។

៤. **ខេត្តឧត្តរមានជ័យ** ÷ វិវាទរវាងប្រជាពលរដ្ឋ និងក្រុមហ៊ុន (ខេមបូឌា) ខេន អេន ស៊ូរហ្គើរ វ៉ែលលី, ក្រុមហ៊ុន ទន្លេស៊ូហ្គើរ ខេន និង ក្រុមហ៊ុនអង្គរ ស៊ូហ្គើរ÷

– នៅអំឡុងឆ្នាំ ២០០៨-២០០៩ ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីការវិនិយោគដំណាំអំពៅចំនួន ១ ៥៣៣ គ្រួសារ ទទួលបានការដោះស្រាយរួច ដោយទទួលបានដីសរុបទំហំ ២ ៧៨៣ ហិកតា និងបានចូលរស់នៅ និងអាស្រ័យផលរហូតមក។

– នៅឆ្នាំ ២០១៥ ក្រុមហ៊ុនវិនិយោគទាំងបីបានបញ្ឈប់គម្រោង និងបានប្រគល់ដីទាំងអស់ដែលធ្លាប់បានទទួលពីរដ្ឋ ជូនរដ្ឋវិញ ដូចមានក្នុងលិខិតលេខ ២៨៣ សជណ ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០១៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។ តាមស្មារតីនៃលិខិតនេះផងដែរ រាជរដ្ឋាភិបាលបានប្រគល់ដីជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តឧត្តរមានជ័យ គ្រប់គ្រងនិងចាត់ចែងជាសមត្ថកិច្ច។

៥. សហគមន៍អឺរ៉ុប អង្គការក្រៅរដ្ឋាភិបាល និងក្រសួង ស្ថាប័នពាក់ព័ន្ធ អបអរសាទរ និងបន្តសហការដោះស្រាយបញ្ចប់ទាំងស្រុងនូវវិវាទរវាងប្រជាពលរដ្ឋ និងក្រុមហ៊ុនដំណាំអំពៅផលិតស្ករសនាំចេញដែលនៅសេសសល់ក្នុងភូមិសាស្ត្រខេត្តចំនួន ៣ គឺ ខេត្តកោះកុង ខេត្តកំពង់ស្ពឺ និងខេត្តព្រះវិហារ។

អាស្រ័យហេតុនេះ សូមសាធារណជនជ្រាបជាព័ត៌មាន។

ថ្ងៃអង្គារ ៥ រោច ខែអស្សុជ ឆ្នាំរកា ព.ស. ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែតុលា គ.ស. ២០១៧